

# ជីវប្រវត្តិសម្តេច ហ៊ុន_សែន

កើតនៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៥២ (ជាផ្លូវការ ថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៥១) នៅឃុំពៀមកោះស្នារ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ក្រោយពីបានបញ្ចប់ថ្នាក់មបមសិក្សានៅក្នុងស្រុកកំណើតរួច នៅឆ្នាំ១៩៦៥ លោកហ៊ុន–សែន បានមករស់នៅទីក្រុងភ្នំពេញក្នុងវត្តនាគវន្ត័ដើម្បីបន្តការសិក្សាថ្នាក់មធ្យមសិក្សា នៅសាលាឥន្ទ្រទេវី។

ក្នុងឆ្នាំ១៩៧០ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាម។ ដើម្បីឆ្លើយតបនឹងការអំពាវនាវរបស់ស្តេច សីហនុ អោយប្រជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងចូលរួមសង្គ្រាមប្រឆាំងនឹងរបបចក្រពត្តិនិយម លោកហ៊ុន–សែន បានចូលរួមចលនាតស៊ូ ដែលបាននាំជ័យជំនះជូនប្រទេសកម្ពុជានៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥។

មួយថ្ងៃមុនជ័យជំនះ គឺថ្ងៃ១៦ មេសា ឆ្នាំ១៩៧៥ លោកហ៊ុន–សែន បានត្រូវរបួសធ្វើអោយពិការនៅភ្នែកឆ្វេង។ ក្រោយពីបានជាសះស្បើយក្រោមការព្យាបាលអស់ជាច្រើនខែ សម្តេចបានរៀបការជាមួយនឹងអ្នកនាងប៊ុន–រ៉ានី។ មិនយូរប៉ុន្មាន

ដោយបានមើលឃើញនូវនយោបាយប្រល័យពូជសាសន៏នៃរបប ប៉ុល ពត ក្នុងឆ្នាំ ១៩៧៧ លោកបានចាកចោលក្រុមគ្រួសារជាទីស្រឡាញ់ម្តងទៀត ដើម្បីដឹកនាំចលនា ក្នុងគោលបំណងរំដោះប្រទេសកម្ពុជានិងប្រជាជន អោយចេញផុតពីរបបប្រល័យពូជសាសន៏។ ក្នុងឆ្នាំ១៩៧៨ លោកបានក្លាយជាសមាជិកស្ថាបនិកមួយរូប នៃរណសិរ្សសង្គ្រោះជាតិកម្ពុជា។ ដោយបានរួមសហការណ៏ ជាមួយចលនាអ្នកស្នេហាជាតិជាច្រើនទៀត និងមានការគាំទ្ររពីសំណាក់កងទ័ពស្ម័គ្រចិត្តវៀតណាម នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រណសិរ្សសង្គ្រោះជាតិកម្ពុជា បានរំដោះប្រទេសកម្ពុជានិងប្រជាជន ចេញពីរបបប្រល័យពូជសាសន៏កម្ពុជាប្រជាធិប្បតេយ្យ។

ចាប់តាំងពីឆ្នាំ១៩៧៩ ដល់ ១៩៩៣ លោកហ៊ុន–សែន បានកាន់កាប់តំណែងជាច្រើនក្នុងរដ្ឋបាលកម្ពុជា ក្នុងសម័យសាធារណរដ្ឋប្រជាមានិត និងរដ្ឋកម្ពុជា។ ធ្វើជារដ្ឋមន្ត្រីក្រសួងការបរទេសនៅឆ្នាំ១៩៧៩ ជាឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេសពីឆ្នាំ១៩៨១ ដល់ ១៩៨៥ រួចធ្វើជានាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងការបរទេសពីឆ្នាំ១៩៨៥ ដល់ ១៩៩១។ លោកហ៊ុន–សែនបាននាំមកនូវសមិទ្ធិផលគួរអោយកត់សំគាល់ជាច្រើនរួមមាន ការបង្កើតអោយមាននូវកិច្ចព្រមព្រៀងសន្តិភាព ការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍន៏ប្រទេសកម្ពុជា។ ឆ្លងតាមការលះបង់និងការប្រឹងប្រែងជាច្រើន លោកហ៊ុន–សែន បង្ហាញចេញនូវស្នាដៃដែលមិនអាចកាត់ថ្លៃបាន គឺការបង្កើតអោយមានកិច្ចព្រមព្រៀងសន្តិភាព នៅទីក្រុងប៉ារីសស្តីពីកម្ពុជា។

ជាលទ្ធផលនៃការខិតខំប្រឹងប្រែងអោយមានកិច្ចព្រមព្រៀង រួមនឹងការបោះឆ្នោតជាតិ ឆ្នាំ១៩៩៣ លោកហ៊ុន–សែនបានបម្រើប្រជាជនកម្ពុជាក្នុងឋានៈជា សហនាយករដ្ឋមន្ត្រីនិងជានាយករដ្ឋមន្ត្រីទីពីរ នៃរដ្ឋាភិបាលចម្រុះភាគីអាណត្តិទីមួយ រវាងឆ្នាំ១៩៩៣ ដល់១៩៩៨។ ក្នុងដំណែងនេះ លោកបានបង្ហាញអោយឃើញជាថ្មីម្តងទៀត គឺជាស្ថាបនិកសមិទ្ធិផលជាតិ និងជាស្ថាបនិកនៃកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស។ សមិទ្ធិផលទាំងនោះរួមមាន ការបំពេញនូវកិច្ចសន្យារស្តីពីការអភិវឌ្ឍន៏បណ្តាញផ្លូវជនបទ សាលារៀន មជ្ឈមណ្ឌលឱសថដ្ឋាននិងសុខភាព និងការបង្កើតអោយមាននូវប្រព័ន្ធទឹកស្អាត។

ក្នុងខែកក្កដា ឆ្នាំ១៩៩៨ ការបោះឆ្នោតជាសាកលបានផ្តល់ជ័យជំនះដល់គណបក្សប្រជាជនកម្ពុជា ដែលមានលោកហ៊ុន–សែន ជាអនុប្រធាន។ លោកក៏បានក្លាយជានាយករដ្ឋមន្ត្រីទោលនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំរដ្ឋាភិបាលចម្រុះភាគីអាណត្តិទីពីរ រវាងគណបក្សប្រជាជន និង ហ៊្វុនស៊ិនប៉ិច រួចក៏បានប្រកាសជាឱឡារិក ថាជារដ្ឋាភិបាលសេដ្ឋកិច្ចមួយ។ ក្រោមការដឹកនាំរបស់លោក ហ៊ុន សែន កម្ពុជាក៏បានក្លាយជាសមាជិកទី១០ នៃសមាគមជាតិ អាស៊ីអាគ្នេយ៏ ហៅកាត់ថាអាស៊ាន។

ដោយសារកិច្ចខិតខំប្រឹងប្រែង និងការលះបង់របស់ខ្លួន ចំពោះការបង្រួបបង្រួមជាតិសន្តិភាព និងការអភិវឌ្ឍន៏សេដ្ឋកិច្ចសង្គមកម្ពុជា លោកហ៊ុន–សែនត្រូវបានប្រគល់កិត្តនាមជា សម្តេច ដោយព្រះមហាក្សត្រ ព្រមទាំងបានទទួលមេដាយសន្តិភាព

ពិភពលោកមួយទៀតផង។ សម្តេចបានទទួល បរិញ្ញាប័ត្រផ្នែកនយោបាយពីមជ្ឈមណ្ឌលអប់រំកម្ពុជា, សញ្ញាប័ត្រថ្នាក់ Ph.D. ផ្នែកនយោបាយសង្គម ចេញពីសាលាបណ្ឌិតសភាននយោបាយ នៅទីក្រុងហាន់ណូយ ឆ្នាំ១៩៩១ ព្រមទាំងបានទទួលងារកិត្តិយសថ្នាក់បណ្ឌិតចំនួនពីរគឺ: Ph.D. ផ្នែកនយោបាយ ចេញពីសកលវិទ្យាល័យភាគខាងត្បូងរដ្ឋកាលីហ្វ័រនៃ SCU សហរដ្ឋអាមេរិក សំរាប់ការសិក្សាជាផ្លូវការ ក្នុងឆ្នាំ១៩៩៥ និង Ph.D. ផ្នែកច្បាប់ពីសកលវិទ្យាល័យអ៊ីយូវ៉ា វេសលីយ៉ាន សហរដ្ឋអាមេរិក ក្នុងឆ្នាំ១៩៩៦។

នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៦ បណ្ឌិតសភាសន្តិភាពពិភពលោក បានប្រគល់រង្វាន់សន្តិភាពពិភពលោក ជូនដល់សម្តេចហ៊ុន-សែន។ សម្តេចគឺជាវីរៈជនទី៦នៅក្នុងពិភពលោក និងជាអ្នកទីមួយប្រចាំនៅអាស៊ីភាគខាងត្បូង ដែលបានទទួលរង្វាន់កិត្តិយសនេះ ដែលក្នុងនោះសម្តេចត្រូវបានប្រគល់នូវឥស្សរៈយសចំនួនបីរួមមាន: ១-ជាធនធានវប្បធម៌មនុស្សលោក, ២-ជាឯកអគរដ្ឋទូតសន្តិភាព និង ៣-ជាសមាជិកព្រឹទ្ធសភាសន្តិភាពពិភពលោក។

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ក្រោយពីបានទទួលស្គាល់នូវការលះបង់ដ៏ធំធេងចំពោះការស្តារឡើងវិញនូវសន្តិភាព និងស្ថេរភាពនៅក្នុងប្រទេសកម្ពុជា ការបង្កើននូវទំនាក់ទំនងការទូតរវាងកម្ពុជានិងសាធារណរដ្ឋកូរេ ព្រមទាំងការខិតខំប្រឹងប្រែងធ្វើអោយមានកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីបូព៌ា គណៈកម្មាធិការផ្តល់រង្វាន់ថ្នាក់បញ្ចប់ការសិក្សា នៃសកលវិទ្យាល័យដានកុកក្នុងប្រទេសកូរេខាងត្បូង បាន

ប្រគល់រង្វាន់ជាកិត្តិយសថ្នាក់បណ្ឌិតផ្នែកនយោបាយសង្គម ជូនដល់សម្តេចហ៊ុន–សែន ។

នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០១ សម្តេច ត្រូវបាន ប្រគល់នូវសញ្ញាប័ត្រជា កិត្តិយសថ្នាក់បណ្ឌិតផ្នែកនយោបាយសង្គមក្នុងវិស័យទំនាក់ទំនងការបរទេស ដោយ សកលវិទ្យាល័យ Ramkhamhaeng នៃប្រទេសថៃ ។

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០១ មជ្ឈមណ្ឌលសន្តិភាពអន្តរជាតិ Sri Chinmoy បាន ប្រគល់សម្តេចនូវ រង្វាន់ស្តីពីការលើកតំកើនពិភពលោកអោយមានការរួមចិត្តតែមួយ ។ រង្វាន់នេះ ត្រូវបាន ប្រគល់ជូនសម្តេច ដើម្បីជាការឆ្លើយតបទៅនឹងសមិទ្ធិផលជាច្រើន ដែលសម្តេចទទួលបានទាំងបរិមាណនិងគុណភាព ។ Sri Chinmoy បានចាត់ទុក សម្តេចហ៊ុន–សែន ថាជា ឧបករណ៍ដែលព្រះពុទ្ធបានជ្រើសតាំង អោយមកជួយ សង្គ្រោះ ប្រជាជនកម្ពុជារាប់លាននាក់អោយចាកផុតពីសេចក្តីស្លាប់ រួចផ្តល់នូវ ចំណេះដឹង អាហារនិងជំរក ការសាងសង់សាលារៀន មន្ទីរពេទ្យ និង ប្រឡាយ ទឹក ព្រមទាំងដឹកនាំកម្ពុជាចូលជាសមាជិកអាស៊ាន ។

នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០២ សម្តេច ត្រូវបានទទួលស្គាល់ជាសមាជិក បណ្ឌិតសភា ផ្នែកសិល្បសាស្រ្តធម្មជាតិ របស់សហព័ន្ធសូវៀត និងបានទទួល មេដាយ ចំពោះការដឹកនាំរបស់សម្តេច ដែលបាននាំមកនូវសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ជូនប្រទេសកម្ពុជា ។
នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០២ គណកម្មាធិការសហព័ន្ធវិស្វកម្មអាស៊ាន (AFF)

បានប្រគល់ងារដល់សម្តេចហ៊ុន–សែន ថាជាសមាជិកមិត្តសំឡាញ់ដ៏មានកិត្តិយសខ្ពង់ខ្ពស់ប្រចាំនៅអាស៊ី ដែលជាកិត្តិនាមខ្ពស់បំផុតហើយពុំដែលធ្លាប់មានកន្លងមក។ ទាំងនេះកើតចេញពីស្មារតីស្នេហាជាតិ និងសមត្ថភាពដឹកនាំប្រទេស ដែលបានបញ្ចប់សង្គ្រាមស៊ីវិល អនុវត្តន៍ការស្តារឡើងវិញលើគ្រប់វិស័យ និងការអភិវឌ្ឍន៍ព្រមទាំងផ្តល់ឱកាសដល់វិស្វករកម្ពុជាក្នុងការចូលរួមដំណើរការស្ថាបនា និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ។

សម្តេចហ៊ុន–សែន និងលោកជំទាវប៊ុនរ៉ានី មានកូនប្រុសបីនាក់ និងកូនស្រីបីនាក់ (ក្នុងចំណោមនោះម្នាក់ជាកូនចិញ្ចឹម) គឺ: ហ៊ុន–ម៉ាណែត, ហ៊ុន–ម៉ាណា ហ៊ុន–ម៉ានិត, ហ៊ុន–ម៉ានី, ហ៊ុន–ម៉ាលី, និង ហ៊ុន–ម៉ាលីស។

To view in English Click Here.